**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ..........................

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

## សេចក្ដីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីវិធានការបន្ថែម សំដៅជួយដល់វិស័យឯកជន និង កម្មករ-និយោជិត ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីការរីករាលដាលនៃជំងឺកូវីដ-១៩, និង វិធានការស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចក្រោយពីវិបត្តិនៃជំងឺនេះ

**(ជុំទី ៤, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០)**

កម្ពុជាគ្រប់គ្រង និង ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ បានយ៉ាងល្អប្រសើរ ខណៈដែលស្ថានភាពនៃការរីករាលដាលនៃជំងឺនេះ ក្នុងកម្រិតតំបន់ និង សកលលោក ក៏ហាក់ដូចជាមានភាពធូរស្បើយជាងមុន ។ ទោះជាយ៉ាងនេះក្ដី, ផលប៉ះពាល់ជាអវិជ្ជមានមកលើសេដ្ឋកិច្ច និង សង្គម ពីការរាតត្បាតនៃជំងឺនេះលើគ្រប់ប្រទេសទាំងអស់ក្នុងសកលលោក រួមទាំងកម្ពុជាផង នៅតែបន្តអូសបន្លាយនៅឡើយ ។

ក្នុងគោលដៅធានាលំនឹងនៃសេដ្ឋកិច្ច និង សង្គម ពិសេសរក្សាលំនឹងអាជីវកម្មរបស់ក្រុមហ៊ុន, រោងចក្រ និង សហគ្រាស ឲ្យអាចបន្តអាជីវកម្ម ឆ្លងផុតពីវិបត្តិនៃជំងឺកូវីដ-១៩ នេះ, រាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញនូវវិធានការជុំទី ៤ ដើម្បីកាត់បន្ថយផលប៉ះពាល់នានាដែលអាជីវកម្ម-ធុរកិច្ចក្នុងវិស័យសំខាន់ៗកំពុងជួបប្រទះ ។ កញ្ចប់នៃវិធានការនេះ រួមបញ្ចូលនូវសមាសភាគធំៗពីរ គឺ៖ (១)-ការបន្តសុពលភាពនៃវិធានការមួយចំនួនដែលរាជរដ្ឋាភិបាលបានដាក់ចេញកន្លងមក; និង (២)-ការដាក់ចេញនូវវិធានការថ្មីបន្ថែម ។ ជាមួយគ្នានេះ, វិធានការជុំទី ៤ នេះ ក៏បានគិតគូរដល់ការបង្កើននូវការចូលរួមចំណែកបន្ធូរបន្ថយ នៃការរស់នៅរបស់ប្រជាពលរដ្ឋ ដែលមានជីវភាពក្រីក្រ តាមរយៈកម្មវិធីជំនួយសង្គម (Social Assistance) ផងដែរ ។

ជាងនេះទៅទៀត, ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ អាចនឹងវិវត្តទៅដល់ដំណាក់កាលមួយដែលកាន់តែធូរស្បើយ ហើយសេដ្ឋកិច្ចអាចដំណើរការបានប្រក្រតីឡើងវិញនាពេលឆាប់ៗខាងមុខ, វិធានការជុំទី ៤ នេះ ក៏ផ្ដោតផងដែរ លើការជួយស្ដារ និង ជំរុញលទ្ធភាពអាជីវកម្ម និង ធុរកិច្ច ឲ្យងើបឡើងវិញ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍ក្រោយវិបត្តិនៃជំងឺនេះ ។

វិធានការជុំទី ៤ ដែលត្រូវបានរៀបចំឡើងក្នុងស្មារតីបុរេសកម្ម និង ដោយមានការពិគ្រោះយោបល់ទូលំទូលាយជាមួយគ្រប់តួអង្គពាក់ព័ន្ធ ដូចបានគូសបញ្ជាក់ខាងលើ រួមមានដូចខាងក្រោម ៖

១. វិធានការជួយរក្សាលំនឹងអាជីវកម្ម និង ជីវភាពកម្មករ-និយោជិត

*១.១. វិធានការបន្តជួយវិស័យទេសចរណ៍*

- បន្តលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ ចំពោះ សណ្ឋាគារ, ផ្ទះសំណាក់, ភោជនីយដ្ឋាន និង ក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និង មានសកម្មភាពអាជីវកម្ម នៅក្នុងរាជធានីភ្នំពេញ, ខេត្តសៀមរាប, ខេត្តព្រះសីហនុ, ខេត្តកែប, ខេត្តកំពត, ក្រុងបាវិត និង ក្រុងប៉ោយប៉ែត សម្រាប់រយៈពេល ២ ខែ បន្ថែមទៀត ចាប់ពីខែ មិថុនា ដល់ខែ កក្កដា ឆ្នាំ ២០២០;
- បន្តអនុញ្ញាតឲ្យមិនបង់ប្រាក់ភាគទានធានារ៉ាប់រងរបបហានិភ័យការងារ និង ថែទាំសុខភាព (បសស) ក្នុងអំឡុងពេលព្យួរអាជីវកម្ម;
- លើកលែងការបង់ថ្លៃបន្តអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទ នៅក្នុងវិស័យទេសចរណ៍ សម្រាប់ឆ្នាំ ២០២១ ។

*១.២. វិធានការជួយវិស័យអាកាសចរណ៍*

- លើកលែងការបង់ពន្ធអប្បបរមា (Minimum tax) សម្រាប់រយៈពេល ២ ខែ បន្តទៀត ចាប់ពីខែ មិថុនា ដល់ខែ កក្កដា ឆ្នាំ ២០២០ ជូនដល់ក្រុមហ៊ុនអាកាសចរណ៍ ដែលបានចុះបញ្ជីនៅកម្ពុជា ។

២. វិធានការផ្តល់ហិរញ្ញប្បទានសម្រាប់អាជីវកម្ម

*២.១. កែសម្រួលកម្មវិធីហិរញ្ញប្បទានពិសេស ៥០ លានដុល្លារអាមេរិក តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) ដោយពង្រីកវិសាលភាពគ្របដណ្តប់ និង កែសម្រួលលក្ខខណ្ឌឥណទាន ដូចខាងក្រោម ៖*

- បន្ថយអត្រាការប្រាក់សម្រាប់កម្ចីទុនបង្វិល (Working Capital) ពី ៦% មក ៥% និង សម្រាប់ទុនវិនិយោគ ពី ៦,៥% មក ៥,៥% ដោយមិនគិតកម្រៃសេវាផ្សេងៗ;
- កែសម្រួលរយៈពេលឥណទានអតិបរមាពី ៥ ឆ្នាំ ទៅ ៧ ឆ្នាំសម្រាប់ទុនវិនិយោគ ខណៈរក្សាទុករយៈពេលខ្ចី អតិបរមា ២ ឆ្នាំ សម្រាប់ទុនបង្វិល;
- បន្តមិនអនុញ្ញាតឱ្យអតិថិជនដែលទទួលកម្ចីនៅក្នុងកម្មវិធីពិសេសនេះ យកកម្ចីទៅប្រើប្រាស់ធ្វើបុនហិរញ្ញប្បទាន (Refinancing);
- ផ្តល់ភាពទន់ភ្លន់លើលក្ខខណ្ឌចុះបញ្ជី ដែលក្នុងនោះ សហគ្រាសធុនតូច និង មធ្យម ដែលមិនទាន់ចុះបញ្ជីផ្លូវការ អាចដាក់ពាក្យស្នើសុំឥណទានបាន ដោយបំពេញលក្ខខណ្ឌចុះបញ្ជីតាមក្រោយ ក្នុងរយៈពេល ១ ខែ បន្ទាប់ពីទទួលបានឥណទាន;

- កែសម្រួលលក្ខខណ្ឌតម្រូវឲ្យ "សហគ្រាសធុនតូច និង មធ្យម បង្កើតឱកាសការងារថ្មីចាប់ពី ៥ នាក់ឡើងទៅ" ទៅជា "លើកទឹកចិត្តឲ្យសហគ្រាសធុនតូច និង មធ្យម ដែលទទួលបានឥណទាន ខិតខំបង្កើតឱកាសការងារថ្មី";
- ពង្រីកវិសាលភាពនៃការផ្តល់ឥណទានក្នុងគម្រោងនេះ ដល់បណ្តុំសហគ្រាសធុនតូច និង មធ្យម (SME Cluster) ដោយលើកទឹកចិត្តសហគ្រាសធុនតូច និង មធ្យម ដែលមានការពាក់ព័ន្ធឲ្យប្រើប្រាស់សេវាបច្ចេកទេសរបស់មជ្ឈមណ្ឌល «សហគ្រិនខ្មែរ» (Khmer Entrepreneur) ដើម្បីសម្រួលដល់ការទទួលបាននូវឥណទាននេះ ។

*២.២. កែសម្រួលកម្មវិធីសហហិរញ្ញប្បទានពិសេស ១០០ លានដុល្លារអាមេរិក រវាងធនាគារសហគ្រាសធុនតូច និង មធ្យម ជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុ ដោយពង្រីកវិសាលភាពគ្របដណ្តប់ និងកែសម្រួលលក្ខខណ្ឌឥណទាន ដូចខាងក្រោម ៖*

- អនុញ្ញាតឲ្យមានការកែសម្រួលលក្ខខណ្ឌឥណទាន ចំពោះឥណទានដែលកំពុងដំណើរការ (Loan Restructuring);
- បន្តមិនអនុញ្ញាតឲ្យអតិថិជនដែលទទួលកម្ចីនៅក្នុងកម្មវិធីពិសេសនេះ យកកម្ចីទៅប្រើប្រាស់ធ្វើបុនហិរញ្ញប្បទាន (Refinancing);
- ផ្តល់ភាពទន់ភ្លន់ក្នុងការសងត្រលប់ ដោយប្តូរពីការតម្រូវឲ្យសងប្រចាំខែ ទៅជាត្រីមាស ឬឆមាស ហើយយ៉ាងយូរបំផុតត្រឹម ១២ ខែ ចំពោះដើមទុន និង ការប្រាក់;
- កែសម្រួលរយៈពេលឥណទានពី ៤ ឆ្នាំ ទៅ ៧ ឆ្នាំ ដោយអនុញ្ញាតឲ្យគ្រឹះស្ថានហិរញ្ញវត្ថុ (PFIs) ជាអ្នកធ្វើការវាយតម្លៃខ្លួនឯង លើរយៈពេលឥណទាន សម្រាប់ឥណទានទុនបង្វិល និង ឥណទានទុនវិនិយោគ;
- ពង្រីកវិសាលភាពនៃការផ្តល់ឥណទាន ឲ្យគ្របដណ្តប់ទៅដល់សហគ្រាសក្នុងវិស័យផលិតឧបករណ៍វេជ្ជសាស្ត្រ និង ផលិតឱសថ បន្ថែមលើវិស័យអាទិភាពដែលមានចែងក្នុងអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ២០១៨ ស្តីអំពី "ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និង មធ្យមក្នុងវិស័យអាទិភាព";
- កែសម្រួលលក្ខខណ្ឌតម្រូវឲ្យ "សហគ្រាសធុនតូច និង មធ្យម បង្កើតឱកាសការងារថ្មីចាប់ពី ៥ នាក់ឡើងទៅ" ទៅជា "លើកទឹកចិត្តឱ្យសហគ្រាសធុនតូច និង មធ្យម ដែលទទួលបានឥណទាន ខិតខំបង្កើតឱកាសការងារថ្មី" ។

៣. ការបង្កើនហិរញ្ញប្បទានបន្ថែម ដើម្បីស្តារ និង ជំរុញកំណើនក្រោយវិបត្តិនៃជំងឺកូវីដ-១៩

*៣.១. វិធានការបង្កើន និង សម្រួលរំហូរសាច់ប្រាក់*

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងសហការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីពិនិត្យលទ្ធភាពបន្ធូរបន្ថយ និង កែសម្រួលនូវលក្ខខណ្ឌមួយចំនួន ដើម្បីបង្កើន និង សម្រួលលំហូរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារថែមទៀត ។

*៣.២.ការបន្ធូរបន្ថយការអនុវត្តពន្ធកាត់ទុកលើការប្រាក់សម្រាប់អ្នកផ្ដល់កម្ចីក្នុងស្រុក និង ក្រៅស្រុក (Withholding Tax)*

សម្រាប់កម្ចីថ្មី :

- ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និង ខាងក្នុងស្រុក, មកនៅត្រឹម ៥% (ទាំងការខ្ចីពីប្រទេសដែលមានកិច្ចព្រមព្រៀងស្ដីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និង ការបង្ការការគេចវេះពន្ធ និងការ-ចៀសវាងពន្ធ (DTA) និង ការខ្ចីពីប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២០;
- ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និងខាងក្នុងស្រុក, មកនៅត្រឹម ១០% (ទាំងការខ្ចីពីប្រទេសដែលមាន DTA និង ការខ្ចីពីប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២១; និង
- កែតម្រូវអត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និង ខាងក្នុងស្រុក, ឱ្យឡើងដល់កម្រិតធម្មតា ស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមានវិញ នៅឆ្នាំ ២០២២ ។

សម្រាប់កម្ចីចាស់ :

- ទម្លាក់អត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និង ខាងក្នុងស្រុក, មកនៅត្រឹម ១០% (ទាំងការខ្ចីពីប្រទេសដែលមាន DTA និង ការខ្ចីពីប្រទេសដែលមិនមាន DTA) សម្រាប់ឆ្នាំ ២០២០;
- កែតម្រូវអត្រាពន្ធកាត់ទុក លើកម្ចីរបស់ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ, ទាំងពីប្រភពខាងក្រៅ និង ខាងក្នុងស្រុក, ឱ្យឡើងដល់កម្រិតធម្មតា ស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមានវិញ នៅឆ្នាំ ២០២១ ។

*៣.៣. ប្រភពហិរញ្ញប្បទានសម្រាប់ទុនបង្វិល (Working Capital)*

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងរៀបចំបង្កើត «មូលនិធិធានាឥណទាន» (Credit Guarantee Fund) ជាមួយថវិកា ២០០ លានដុល្លារអាមេរិក ។ មូលនិធិនេះ អាចធានាឥណទានកម្ចីតាមរយៈធនាគារ និង មីក្រូហិរញ្ញវត្ថុ ដោយប្រើគោលការណ៍ទីផ្សារ ដើម្បីជួយសម្រាលសម្ពាធលំហូរសាច់ប្រាក់ និង ទុនបង្វិលរបស់អាជីវកម្ម-ធុរកិច្ចក្នុងគ្រប់វិស័យ បានយ៉ាងតិចចំនួន ២.០០០ លានដុល្លារអាមេរិក ។

*៣.៤. ត្រៀមឧបករណ៍ផ្តល់ហិរញ្ញប្បទាន ( Financing Facility ) បន្ថែម*

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងត្រៀមថវិកាសម្រាប់ហិរញ្ញប្បទានបន្ថែមចំនួន ៣០០ លានដុល្លារអាមេរិក ដើម្បីគាំទ្រ និង ដើរតួជាកាតាលីករជំរុញកំណើនតាមវិស័យសំខាន់ៗ ក្នុងអំឡុងពេលវិបត្តិ និង ក្រោយពេលវិបត្តិ ។

## ៤. វិធានការជំនួយសង្គម

- រាជរដ្ឋាភិបាលសម្រេចពង្រីកវិសាលភាពគ្របដណ្តប់ និង ទំហំថវិកា សម្រាប់ «**កម្មវិធីសាច់ប្រាក់ពលកម្ម**» ( Cash for Work ) នៅក្នុងឆ្នាំ ២០២០ ឲ្យឡើងដល់ ១០០ លានដុល្លារអាមេរិក ដើម្បីស្រូបយកកម្លាំងពលកម្ម ដែលបាត់បង់ការងារពីរោងចក្រ-សហគ្រាស និង ដែលបានវិលត្រលប់ពីបរទេសមកស្រុកកំណើតវិញផង ព្រមទាំងដើម្បីជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានជាទូទៅផង និង ដើម្បីបង្កើតនូវសមិទ្ធផលសង្គម-សេដ្ឋកិច្ច តាមរយៈការអនុវត្តគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតូចៗនៅតាមមូលដ្ឋាន សំដៅលើកស្ទួយវិស័យកសិកម្ម និង សេដ្ឋកិច្ចផងដែរ;

- ជាមួយនឹងការបន្តផ្តាបន្តអនុវត្តរាល់កម្មវិធីគាំពារសង្គមទាំងឡាយដែលមានស្រាប់ មិនឲ្យខកខាន, រាជរដ្ឋាភិបាលនឹងរៀបចំដាក់ឲ្យអនុវត្ត នៅក្នុងខែ មិថុនា ឆ្នាំ ២០២០ នេះ នូវកម្មវិធីជំនួយសង្គមសំដៅជួយសម្រួលជីវភាពប្រចាំថ្ងៃ នៅក្នុងអំឡុងពេលនៃវិបត្តិដោយសារជំងឺកូវីដ-១៩ នេះ ជូនដល់គ្រួសារប្រជាពលរដ្ឋក្រីក្រ និង ក្រុមជនងាយរងគ្រោះ ដែលមានបណ្ណសមធម៌ទូទាំងប្រទេសដោយយកចិត្តទុកដាក់បន្ថែមដល់កុមារអាយុក្រោម ៥ ឆ្នាំ, ជនពិការ, ជនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំឡើង និង អ្នកផ្ទុកមេរោគអេដស៍ នៅក្នុងគ្រួសារប្រជាពលរដ្ឋក្រីក្រទាំងនោះផងដែរ ។

## ៥. ការដាក់ឱ្យអនុវត្តថ្នាលចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក

- រាជរដ្ឋាភិបាលនឹងដាក់ឲ្យដំណើរការជាជំហានទី ១ នូវថ្នាលចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក ( IT Business Registration Platform ) នៅដើមខែ មិថុនា ឆ្នាំ ២០២០ នេះ ដើម្បីសម្រួល និង ជំរុញដល់ការចុះបញ្ជីក្រុមហ៊ុនជាទូទៅ និងជាពិសេសជួយសម្រួលដល់ក្រុមហ៊ុនទាំងឡាយណាដែលមានបំណងចុះបញ្ជី ដើម្បីទទួលបានកម្ចីពីកម្មវិធីហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល ។

ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តនូវសេចក្តីណែនាំនេះ ទៅតាមសមត្ថកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

រាជរដ្ឋាភិបាលនឹងបន្តតាមដានយ៉ាងខ្ជាប់ខ្ជួននូវសភាពការណ៍ផលប៉ះពាល់ពីជំងឺកូវីដ-១៩ លើសេដ្ឋកិច្ច និង សង្គមជាតិ និង ត្រៀមជាស្រេចក្នុងការដាក់ចេញវិធានការបន្ថែមទៀត ដើម្បីផ្តល់នូវការជួយគាំទ្រសមស្រប និង តាមការចាំបាច់ ដល់ក្រុមហ៊ុនអាជីវកម្ម, កម្មករ-និយោជិត និង ក្រុមប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ។